ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

L202308090327TD3802

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## កិច្ចប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈ នៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគាររីង (ខេមបូឌា) ម.ក សម្រាប់ប្រតិបត្តិការទទួលចំណូលពន្ធដារអនុវត្ត នៅទូទាំងប្រទេស រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគាររីង (ខេមបូឌា) ម.ក

ថ្ងៃចន្ទ ១៣ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
អគ្គនាយកដ្ឋានពន្ធដារ ថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣




© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នារសៀលថ្ងៃចន្ទ ១៣ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី១៤ ខែសីហា ឆ្នាំ២០២៣ ឯកឧត្តមបណ្ឌិត **កែន សម្បត្តិ** អគ្គនាយករងនៃអគ្គនាយកដ្ឋានពន្ធដារ និងជាប្រធានក្រុមការងារដើម្បីពិភាក្សាកិច្ចការបច្ចេកទេសក្នុងការផ្តល់សេវាទទួលប្រាក់ពន្ធ-អាករគ្រប់ប្រភេទតាមធនាគារពាណិជ្ជ បានដឹកនាំប្រជុំពិនិត្យ និងពិភាក្សាលើសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការប្រើប្រាស់សេវាកម្មរបស់ធនាគាររីង (ខេមបូឌា) ម.ក សម្រាប់ប្រតិបត្តិការទទួលចំណូលពន្ធដារអនុវត្តនៅទូទាំងប្រទេស រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគាររីង (ខេមបូឌា) ម.ក នៅទីស្តីការនៃអគ្គនាយកដ្ឋានពន្ធដារ។ កិច្ចប្រជុំនេះ មានការចូលរួមពីសំណាក់លោកអនុប្រធាន លោក លោកស្រី

សមាជិកនៃក្រុមការងារដើម្បីពិភាក្សាកិច្ចការបច្ចេកទេស ក្នុងការផ្ដល់សេវាទទួលប្រាក់ពន្ធ-អាករគ្រប់ប្រភេទតាមធនាគារពាណិជ្ជអមដោយមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ និងតំណាងធនាគាររីង (ខេមបូឌា) ម.ក ដឹកនាំដោយលោក **ឈុន ចន្ទ្រានត្ថិ** អគ្គនាយករងនៃធនាគាររីង (ខេមបូឌា) ម.ក និងអមដោយបុគ្គលិកជំនាញពាក់ព័ន្ធនៃធនាគារនេះ។

ជាកិច្ចចាប់ផ្ដើម ឯកឧត្តមបណ្ឌិតអគ្គនាយករង បានសម្ដែងនូវកិច្ចស្វាគមន៍ និងការវាយតម្លៃខ្ពស់ចំពោះលោក លោកស្រី តំណាងធនាគាររីង (ខេមបូឌា) ម.ក ដែលបានអញ្ជើញចូលរួមប្រជុំពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នានេះ តាមការអញ្ជើញ។ នាឱកាសនោះ ឯកឧត្តមបណ្ឌិតអគ្គនាយករងបានលើកឡើងពីការដាក់ចេញឱ្យមានការបង់ពន្ធតាមប្រព័ន្ធធនាគារពាណិជ្ជដៃគូនេះ គឺជាយន្តការមួយក្នុងការជួយសម្រួលសេវាបង់ពន្ធក៏ដូចជាបង្កិតសេវាបង់ពន្ធឱ្យទៅជិតអ្នកជាប់ពន្ធ សំដៅឱ្យអ្នកជាប់ពន្ធមានភាពងាយស្រួលក្នុងការបង់ពន្ធ ជាពិសេសនៅពេលមានវិបត្តិនៃជំងឺកូវីដ-១៩ ផ្ទុះឡើង ដែលអនុញ្ញាតឱ្យអ្នកជាប់ពន្ធអាចធ្វើការប្រកាសនិងបង់ប្រាក់ពន្ធតាមរយៈប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន e-Filing និង e-Payment ពីគេហដ្ឋាន ឬការិយាល័យរបស់ខ្លួន ឬពីទីតាំងណាមួយក៏បានឱ្យតែមានប្រព័ន្ធ Internet ដោយមិនចាំបាច់ធ្វើដំណើរមកជួបផ្ទាល់ជាមួយមន្ត្រីរដ្ឋបាលពន្ធដារ ឬបុគ្គលិកសាខាធនាគារពាណិជ្ជដៃគូឡើយ។ ឯកឧត្តមបណ្ឌិតអគ្គនាយករងបានបញ្ជាក់បន្ថែមថា បច្ចុប្បន្នមានធនាគារពាណិជ្ជចំនួន ១០ ដែលបានចុះអនុស្សរណៈនៃការយោគយល់គ្នាជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការប្រើប្រាស់សេវាកម្មរបស់ធនាគារទាំងនោះ សម្រាប់ប្រតិបត្តិការទទួលចំណូលពន្ធអនុវត្តនៅទូទាំងប្រទេស ក្នុងនោះក៏មានធនាគាររីង (ខេមបូឌា) ម.ក ដែលបានចុះអនុស្សរណៈជាមួយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការប្រើប្រាស់សេវាកម្មរបស់ធនាគាររីង (ខេមបូឌា) ម.ក សម្រាប់ប្រតិបត្តិការចំណូលពន្ធតែពីរប្រភេទពន្ធ គឺពន្ធលើអចលនទ្រព្យ និងពន្ធលើមធ្យោបាយដឹកជញ្ជូន ព្រមទាំងប្រាក់ពិន័យទោសទណ្ឌនៃប្រភេទពន្ធនីមួយៗ។ ការអនុញ្ញាតឱ្យធនាគារពាណិជ្ជដៃគូផ្ដល់សេវាទទួលប្រាក់ពន្ធនេះ គឺស្ថិតក្នុងក្របខ័ណ្ឌនៃការអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងយុទ្ធសាស្ត្រកៀរគរចំណូលរបស់រាជរដ្ឋាភិបាល ដែលតម្រូវឱ្យស្ថាប័នប្រមូលចំណូលខិតខំផ្ដល់សេវាសាធារណៈឱ្យបានកាន់តែមានភាពងាយស្រួល បង្កិតសេវាទៅជិតអ្នកជាប់ពន្ធ ឬសាធារណជន ធានាបាននូវតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់។

ក្នុងឱកាសនៃកិច្ចប្រជុំ លោក **ឈុន ចន្ទ្រានត្ថិ** អគ្គនាយករងនៃធនាគាររីង (ខេមបូឌា) ម.ក បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **គន់ ឋិបុល** រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រីនិងជាប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដែលបានចាត់ថ្នាក់ដឹកនាំ និងមន្ត្រីជំនាញពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារឱ្យជួបប្រជុំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់នេះ។

ជាកិច្ចបន្ទាប់ អង្គប្រជុំបានពិនិត្យ ពិភាក្សា និងសម្រេចឯកភាពលើសេចក្ដីព្រាងអនុស្សរណៈនៃការយោគយល់គ្នាស្ដីពីការប្រើប្រាស់សេវាកម្មរបស់ធនាគាររីង (ខេមបូឌា) ម.ក សម្រាប់ប្រតិបត្តិការទទួលចំណូលពន្ធ អនុវត្តនៅទូទាំងប្រទេស រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងធនាគាររីង (ខេមបូឌា) ម.ក និងសម្រេចគោរពស្នើសុំឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី មេត្តាពិនិត្យនិងសម្រេចដ៏ខ្ពង់ខ្ពស់ លើកសំណើសុំថ្នាក់ដឹកនាំនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំនៃធនាគាររីង (ខេមបូឌា) ម.ក ដើម្បីពិនិត្យនិងចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់នេះ សំដៅអាចឈានទៅចាប់ផ្ដើមអនុវត្តតាមការគ្រោងទុកនាពេលខាងមុខ។

កិច្ចប្រជុំនេះបានបញ្ចប់ នៅវេលាម៉ោង ១៧ និង ០០ នាទី នាថ្ងៃខែឆ្នាំដដែល ដោយទទួលបានលទ្ធផលជាផ្លែផ្កា ក្រោមស្មារតីកិច្ចសហប្រតិបត្តិការនិងការទទួលខុសត្រូវខ្ពស់៕